# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីប្រធានបទថា ព្រះពុទ្ធសាសនាប្រៀបមកវិទ្យាសាស្ត្រ

web site: hoksavann.org

ថ្ងៃទី២ កញ្ញា ២០០៦

ព្រះពុទ្ធព្រះបរមគ្រូព្រះអង្គត្រាស់ដឹងនូវហេតុផលទូទៅ ឬហេតុផលសព្វគ្រប់ដែលហៅថាសព្វញ្ញុតញ្ញាណ ។ ហេតុផលមួយភាគដូចហេតុផលរបស់វិទ្យាសាស្ត្រ ហើយហេតុផលជាច្រើនទៀតវិទ្យាសាស្ត្រពុំមាន ។ ព្រះពុទ្ធសំដែងអំពីហេតុផលតាមរូបធាតុផងនិងនាមធាតុ គឺចិត្តចេតសិកផង ។ ចំណែកវិទ្យាសាស្ត្រសំដែងជាពិសេសអំពីរូបធាតុ ។

ថ្ងៃមួយព្រះអង្គបានយាងធ្វើដំណើរជាមួយអានន្ទ បានឈប់នៅក្រោមម្លប់ដើមឈើមួយដើម ព្រះអង្គបានក្តាប់ស្លឹកឈើមួយក្តាប់ ហើយសួរព្រះអានន្ទជាប្រស្នាថា ម្នាលអានន្ទ ស្លឹកឈើនៅដៃតថាគត និងស្លឹកឈើដែលធ្លាក់ពាសពេញលើផែនដី តើស្លឹកឈើណាច្រើនជាង ? ព្រះអានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចំរើន ស្លឹកឈើដែលនៅលើព្រះហត្ថព្រះអង្គមានចំនួនតិចណាស់ ចំណែកស្លឹកឈើដែលធ្លាក់នៅពាសពេញផែនដី មានចំនួនច្រើនណាស់ពុំអាចរាប់ចំនួនបានឡើយ ។ ពេលនោះព្រះពុទ្ធសំដែងថា ពិតមែនហើយអានន្ទ ធម៌ដែលតថាគតបានសំដែងប្រោសសត្វមានចំនួនតិចណាស់ ដូចស្លឹកឈើនៅលើព្រះហត្ថតថាគត ចំណែកធម៌ដែលតថាគតបានត្រាស់ដឹង ហើយមិនបានសំដែងប្រាប់សត្វ មានចំនួនច្រើនណាស់ដូចស្លឹកឈើដែលនៅពាសពេញលើផែនដី ម្នាលអានន្ទតថាគតសំដែងតែធម៌ណា ដែលនាំទៅរកការរំដោះទុក្ខរបស់សត្វទាំងឡាយ ដូចតថាគតសំដែងអំពីអរិយសច្ច៤ មានទុក្ខសច្ចជាដើម ។

ព្រះពុទ្ធសំដែងថា វត្ថុទាំងអស់ក្នុងលោក ទាំងមានវិញ្ញាណទាំងគ្មានវិញ្ញាណសុទ្ធតែកើតមកពីគ្រឿងផ្សំ ដែលបាលីហៅថា សង្ខារ បារាំងថា Corps composé អង់គ្លេសថា Component ។ បានសេចក្តីថា វត្ថុធម្មជាតិមនុស្សសត្វទាំងអស់កើតលើងពីគ្រឿងផ្សំ ពុំមែនជាតួខ្លួនវាពិតទេ ប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា កើតឡើងហើយ តែងរលត់ទៅវិញជាធម្មតា ។ ពាក្យព្រះពុទ្ធថា អ្វីទាំងអស់កើតឡើងពី

គ្រឿងផ្សំ ដែលហៅថាសង្ខារនោះ ចាត់ទុកជាមូលដ្ឋាននៃវិទ្យាសាស្ត្រ ព្រោះអ្នកប្រាជ្ញវិទ្យាសាស្ត្រផ្នែករូបវិទ្យាក្តី គីមីវិទ្យាក្តី រកឃើញថា វិត្ថុធាតុទាំងអស់កើតឡើងពីគ្រឿងផ្សំដោយធាតុយ៉ាងល្អិត ដែលហៅថាបរមាណូ (atom) ដែលផ្តុំគ្នាច្រើនកើតជាកោសិកា (molecule) ហើយវត្ថុធាតុម្យ៉ាងកើតឡើងដោយខ្លួនវា ដូចជាទឹកដីភ្លើងខ្យល់ព្រះអាទិត្យព្រះច័ន្ទជាដើម គ្មានអ្នកណាបង្កើតទេ គឺកើតឡើងតាមធម្មតារបស់លោកធាតុ ។ វត្ថុធាតុម្យ៉ាងទៀត កើតឡើងពីបញ្ញារបស់មនុស្ស យកវត្ថុផ្សេងៗមកផ្សំគ្នា ដើម្បីបង្កើតជាទីលំនៅ ប្រដាប់ប្រដាប្រើប្រាស់ គ្រឿងបរិភោគជាដើម ដូចជាផ្ទះសម្បែង រថយន្ត អាកាសយាន ចំណីអាហារគ្រប់យ៉ាងជាដើម ។ ត្រង់ផ្នែករូបធាតុនេះ ព្រះពុទ្ធសាសនានិងវិទ្យាសាស្ត្រមានហេតុផលស្របគ្នា ។

នៅក្នុងបរមត្ថអភិធម្មរបស់ព្រះពុទ្ធសាសនាផ្នែករូប បាននិយាយអំពីអវិនិព្ភោគរូប៨គឺ បឋវី អាបោ តេជោ វាយោ គន្ធោរសោ វណ្ណោរសោ ឱជា តែងនៅជាមួយគ្នាពុំអាចបែងចែកឲ្យដាច់ពីគ្នាបានឡើយ ត្រង់នេះហើយដែលស្របនឹងវិទ្យាសាស្ត្រថា វត្ថុល្អិតដែលជាបរមាណូ ពុំអាចញែកឲ្យដាច់ពីគ្នា ដូចពុទ្ធសាសនាពោលដែរ ។ ដោយព្រះពុទ្ធសាសនានិងវិទ្យាសាស្ត្រមានន័យស្របគ្នា រវាងហេតុនិងផលនេះហើយ ដែលអាចនិយាយបានថា ទៅអនាគតទៀត បើអ្នកវិទ្យាសាស្ត្ររកឃើញការពិតនេះកាន់តែច្រើនឡើង នោះនឹងធ្វើឲ្យគេយល់ការពិតរបស់ព្រះពុទ្ធសាសនា កាន់តែជ្រៅជ្រះឡើងដែរ ។ បានសេចក្តីថា បើគេជឿហេតុផលរបស់វិទ្យាសាស្ត្រ ក៏ទុកដូចជាគេជឿហេតុផលរបស់ព្រះពុទ្ធសាសនាដែរ ។ ត្រង់នេះបញ្ជាក់ថា ពុទ្ធសាសនិកជនខ្មែរមានវិចារណញ្ញាណដ៏ជ្រៅ ក្នុងការជ្រើសរើសជំនឿរបស់ខ្លួនចំពោះព្រះពុទ្ធសាសនា ដែលជាសាសនាមានហេតុផលតាមលក្ខណៈវិទ្យាសាស្ត្រ ដែលខុសគ្នាតែត្រង់វិទ្យាសាស្ត្រស្វែងរកសុខឲ្យមនុស្សនិងសង្គមមនុស្ស ជាលោកសច្ចៈ ចំ-ណែកព្រះពុទ្ធសាសនារកសុខឲ្យមនុស្សនិងសង្គមមនុស្ស មិនត្រឹមលោកបច្ចុប្បន្ននេះទេ ថែមទាំងរកសុខឲ្យមនុស្សជាលោកុត្តរសច្ចៈ ឬនិព្វានសច្ចៈ រំលត់សេចក្តីទុក្ខទាំងស្រុងតែម្តង ។

ភាពស្របគ្នារវាងព្រះពុទ្ធសាសនានិងវិទ្យាសាស្ត្រគឺ ជំនឿត្រូវតែស្ថិតនៅលើហេតុផល ហើយផលណាមួយកើតឡើងមកពីមានហេតុ ។ ពុទ្ធសាសនានិយាយអំពីត្រៃលក្ខណធម៌ អនិច្ចំ ទុក្ខំ និងអនត្តា ដែលជាលក្ខណៈរបស់វត្ថុធាតុទាំងអស់ទាំងមានវិញ្ញាណ ទាំងគ្មានវិញ្ញាណ ចំណែកវិទ្យាសាស្ត្រនិយាយថា វត្ថុទាំងឡាយតែងមានការផ្លាស់ប្តូរតាមការពិសោធន៍ផ្នែករូបវិទ្យា និងគីមីវិទ្យា ។ ពុទ្ធសាសនានិយាយថា ផលវិបាកដែលកើតចេញបីហេតុមួយហើយ អាចជាហេតុនៃផលវិបាកដទៃតទៅទៀត ដែលមាននិយាយក្នុងវដ្តៈ៣គឺ កិលេសវដ្តៈ អវិជ្ជាវដ្តៈ ឧបាទាន អាចកើតមានកម្មវដ្តៈ ការកសាងកម្មហើយកើតវិបាកវដ្តៈ គឺផលរបស់កម្ម ។ ចំណែកវិទ្យាសាស្ត្រនិយាយថា រុក្ខជាតិគ្រប់ប្រភេទ ដែលដុះលូតលាស់ចេញជាដើមផ្លែផ្កា

មកពីជះគឺពូជរបស់វាផ្សំនិងការដាំលើដីដែលមានជីរជាតិល្អផង ។ ពុទ្ធសាសនានិ-
យាយថា មនុស្សសត្វកើតពីធាតុទាំង៤ គឺធាតុទឹកដីភ្លើងខ្យល់ ចំណែកវិទ្យាសា-
ស្ត្រក៏និយាយថា មនុស្សសត្វកើតពីគ្រឿងផ្សំដោយធាតុផ្សេងៗដែរ ។ ត្រង់នេះព្រះ
ពុទ្ធសាសនានិយាយលើសវិទ្យាសាស្ត្រ ត្រង់កំណើតរបស់មនុស្សសត្វត្រូវមាន វិ-
បាកវិញ្ញាណរបស់សត្វមកចាប់បដិសន្ធិផង ។ ព្រះពុទ្ធសាសនានិយាយថា ពិភព-
លោកមានសែនកោដិចក្រវាឡ ឬសែនកោដិលោកធាតុ, ចំណែកវិទ្យាសាស្ត្រក៏និ-
យាយដូចគ្នា តាមការឆ្លុះមើលក្នុងអវកាស ថាមានលោកធាតុដទៃទៀតជាច្រើនរាប់
មិនអស់ ដែលហៅថា galaxy ក្នុងសកលចក្រវាឡ Universe ។ ប៉ុន្តែវិទ្យាសាស្ត្រ
ខុសពីពុទ្ធសាសនា ត្រង់មិនសូវគិតពីសីលធម៌ ដូចជាបង្កើតគ្រឿងសាស្ត្រាវុធ គ្រា
ប់បែកគ្រប់ធុន រហូតបង្កើតគ្រាប់បែកបរមាណូ ដើម្បីឲ្យមនុស្សយកទៅសម្លាប់គ្នា
។ ចំណែកព្រះពុទ្ធវិញ គ្រឿងប្រល័យមនុស្សទាំងនេះ ព្រះពុទ្ធបានហាម ថែមទាំង
ព្រះអង្គបានប្រកាសថា សេចក្តីសុខគ្រប់យ៉ាង កើតពីការស្ងប់មិនធ្វើអំពើបាប គឺការ
មិនបៀតបៀនគ្នានោះឯង ។៚

❑ ❑

❑